# Special Economic Zones in the Mekong Region

Advocacy Note

*(Khmer Language)*



EarthRights International

icj International Commission of Jurists

LAND WATCH THAI

*(This document is an unofficial Khmer translation of a document prepared in English)*

# កំណត់សម្គាល់នៃការតស៊ូមតិ

# តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងតំបន់មេគង្គ

---

## សាវតា

តំបន់សេដ្ឋកិច្ចពិសេស (ត.ស.ព) គឺជាទីតាំងភូមិសាស្ត្រដែលរដ្ឋាភិបាលកំណត់ដើម្បីជួយសម្រួលដល់សកម្មភាពឧស្សាហកម្ម តាមរយៈការលើកទឹកចិត្តផ្នែកសារពើពន្ធនិងបទប្បញ្ញត្តិ និងការទ្រទ្រង់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ[1] ហើយនៅក្នុងនោះ មានច្បាប់ដាច់ដោយឡែកមួយសម្រាប់គ្រប់គ្រងសកម្មភាពវិនិយោគ និងអាជីវកម្ម។ ក្នុងករណីមួយចំនួន គេ បានបង្កើតស្ថាប័នរដ្ឋបាល និងអភិបាលកិច្ច ក៏ដូចជាក្របខ័ណ្ឌនីតិប្បញ្ញត្តិដាច់ដោយឡែក ដើម្បីជួយសម្រួលដល់ការវិនិយោគ និងជៀសវាងភាពយឺតយ៉ាវផ្នែកការិយាធិបតេយ្យ។

ការបង្កើតនិងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស គឺជាចំណុចស្នូលនៃយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលជាច្រើននៅអាស៊ីអាគ្នេយ៍ ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងដើម្បីទាក់ទាញការវិនិយោគពីបរទេស។ ខណៈពេលដែលប្រទេសសមាជិកអាស៊ានភាគច្រើន[2] ដែលរួមមានកម្ពុជា សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (ហៅកាត់ថា 'CLMTV') ជ្រើសរើសតំបន់សេដ្ឋកិច្ចពិសេសដើម្បីធ្វើជាយុទ្ធសាស្ត្រទាក់ទាញវិនិយោគិន បង្កើតការងារ និងបង្កើនប្រាក់ចំណូលពីការនាំចេញ។ ជាក់ស្តែង មានភស្តុតាងជាច្រើន ដែលបង្ហាញថា តំបន់សេដ្ឋកិច្ចពិសេស មិនសុទ្ធតែនាំមកនូវផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចសុទ្ធដល់រដ្ឋម្ចាស់ផ្ទះទាំងអស់នោះទេ។[3]

គោលការណ៍ណែនាំមួយចំនួន ពិភាក្សាអំពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មស្រដៀងគ្នាផ្សេងៗទៀត ដោយបញ្ជាក់យ៉ាងច្បាស់ថា អភិបាលកិច្ច ការអនុលោមតាមសិទ្ធិមនុស្ស ការអនុវត្តការងារស្របច្បាប់ ការការពារនិងអភិរក្សបរិស្ថាន ក៏ដូចជាការចូលរួមនិងការអភិវឌ្ឍន៍សហគមន៍ គឺជាកត្តាស្នូលនៃការស្ថាបនានិងប្រតិបត្តិការរបស់តំបន់ទាំងនេះ ។[4]

គោលការណ៍ណែនាំមួយចំនួន ពិភាក្សាអំពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មស្រដៀងគ្នាផ្សេងៗទៀត ដោយបញ្ជាក់យ៉ាងច្បាស់ថា អភិបាលកិច្ច ការអនុលោមតាមសិទ្ធិមនុស្ស ការអនុវត្តការងារស្របច្បាប់ ការការពារនិងអភិរក្សបរិស្ថាន ក៏ដូចជាការចូលរួមនិងការអភិវឌ្ឍន៍សហគមន៍ គឺជាកត្តាស្នូលនៃការស្ថាបនានិងប្រតិបត្តិការរបស់តំបន់ទាំងនេះ ។

---

[1] United Nations Conference on Trade and Development (UNCTAD), 'World Investment Report 2019: Special Economic Zones', UN, 2019, នៅទំព័រ 128, មាននៅក្នុងគេហទំព័រ៖ https://unctad.org/en/PublicationsLibrary/wir2019_en.pdf

[2] សម្រាប់ព័ត៌មានបន្ថែម, សូមមើលក្នុងគេហទំព័រ៖ https://asean.org/about-asean/member-states/

[3] សូមមើល UNCTAD's World Investment Report 2019, supra note 1

[4] ជាក់ស្តែង សូមមើល UNCTAD's World Investment Report 2019, supra note 1; UNIDO, 'Leveraging a New Generation of Industrial Parks and Zones for Inclusive and Sustainable Development: Strategic Framework', 2018, មាននៅក្នុងគេហទំព័រ៖ https://hub.unido.org/sites/default/files/publications/UNIDO_Strategic%20Framework_WEB.pdf.

យ៉ាងណាមិញ នៅកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ដែលសុទ្ធតែជាភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិមួយចំនួន ក្នុងនោះរួមមានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ហៅកាត់ថា ICESCR) – ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសក្នុងករណីភាគច្រើន ត្រូវបានផ្សារភ្ជាប់ទៅនឹងការថយចុះនៃការធានាដោយច្បាប់សម្រាប់ការការពារសិទ្ធិមនុស្សនិងបរិស្ថាន។ ជាការពិតណាស់ ដោយសារខ្វះការការពារដោយផ្លូវច្បាប់ និង/ឬការអនុវត្តឲ្យបានគ្រប់គ្រាន់ របាយការណ៍នៃការរំលោភសិទ្ធិមនុស្សនិងការរំលោភសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ គឺជារឿងដែលឧស្សាហ៍កើតឡើង នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសដែលមានទីតាំងនៅតំបន់ដីសណ្តទន្លេមេគង្គ។

**<u>បទដ្ឋាននិងច្បាប់អន្តរជាតិពាក់ព័ន្ធ</u>**

នៅក្នុងបរិបទនៃតំបន់សេដ្ឋកិច្ចពិសេស បញ្ហាទាំងស្រុងទាក់ទងនឹង សិទ្ធិស៊ីវិល សិទ្ធិវប្បធម៌ សិទ្ធិសេដ្ឋកិច្ច សិទ្ធិនយោបាយ និងសិទ្ធិសង្គម ទទួលរងឥទ្ធិពលនៅពេលដែលកង្វល់របស់បុគ្គលនិងសហគមន៍ មិនត្រូវបានគេយកមកពិចារណាឲ្យបានសព្វគ្រប់ជ្រុងជ្រោយដោយច្បាប់និងអ្នកតាក់តែងគោលនយោបាយ។

សិទ្ធិទាំងនេះ រួមមានសិទ្ធិទទួលបានបទដ្ឋាននៃការរស់នៅសមរម្យដែលធានាដោយកតិកាសញ្ញា ICESCR ក្នុងនោះរួមមានអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន និងការអភិវឌ្ឍន៍លក្ខខណ្ឌរស់នៅជាបន្តបន្ទាប់។ គេ បំផ្លាញការប្រើប្រាស់សិទ្ធិទាំងនេះ ដោយការមិនឲ្យប្រជាពលរដ្ឋមានលទ្ធភាពទទួលបានមធ្យោបាយនានាដើម្បីស្វែងរកអាហារ រួមទាំងសិទ្ធិទទួលបានដីធ្លី និងធនធាននានាដែលមិនអាចខ្វះបានសម្រាប់ប្រកបជីវភាពរស់នៅរបស់ពួកគេផងដែរ។ បណ្តាប្រទេស CLMTV ក៏មានកាតព្វកិច្ចនៅក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើន រួមទាំងកតិកាសញ្ញា ICESCR ផងដែរ ដើម្បីចៀសវាងនិងទប់ស្កាត់ការបណ្តេញចេញដោយបង្ខំ។ គេ អាចធ្វើការបណ្តេញពួកគេចេញបានជាមធ្យោបាយចុងក្រោយ លុះត្រាតែគេបានអនុវត្តនិងគោរពនូវការការពារតាមនីតិវិធីសមស្រប និងនៅពេលដែលគេ អស់ជម្រើសហើយ។

កតិកាសញ្ញា ICESCR ក៏បានកំណត់អំពីសិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបានបទដ្ឋានសុខភាពផ្លូវកាយនិងផ្លូវចិត្តក្នុងកម្រិតខ្ពស់បំផុតតាមដែលអាចសម្រេចបាន ដែលក្នុងនោះរួមមានការអភិវឌ្ឍន៍នូវគ្រប់ទិដ្ឋភាពទាំងអស់នៃអនាម័យផ្នែកបរិស្ថាននិងឧស្សាហកម្ម។ នៅក្រោមច្បាប់ស្តីពីសិទ្ធិមនុស្ស រដ្ឋ ក៏មានកាតព្វកិច្ចជាមូលដ្ឋាន ទាក់ទងនឹងការទទួលបានបរិស្ថានដែលមាននិរន្តរភាព  សុវត្ថិភាព អនាម័យ និងសុខភាពល្អ ដែលរដ្ឋ មានកាតព្វកិច្ចក្នុងការធ្វើការវាយតម្លៃជាមុនអំពីលទ្ធភាពនៃផលប៉ះពាល់ផ្នែកបរិស្ថានបណ្តាលមកពីគម្រោងនិងគោលនយោបាយដែលបានគេដាក់ស្នើ។

សិទ្ធិទទួលបានការងារ និងសិទ្ធិនៅកន្លែងធ្វើការ ត្រូវបានការពារក្រោមកតិកាសញ្ញា ICESCR ។ បទដ្ឋានអន្តរជាតិស្តីពីសិទ្ធិការងារ រួមទាំងសិទ្ធិក្នុងការបង្កើតនិងចូលរួមសហជីព ក៏ត្រូវបានធានាដោយលិខិតូបករណ៍មួយចំនួនទៀត រួមមានអនុសញ្ញានិងលិខិតូបករណ៍ជាអនុសាសន៍ ដែលត្រូវបានអនុម័តក្រោមការជួយជ្រោមជ្រែងរបស់អង្គការពលកម្មអន្តរជាតិ (ហៅកាត់ថា ILO) ផងដែរ។[5]

[5]កម្ពុជា គឺជាភាគីនៃ C087, C098, C029, C105, C100, C111, C138 and C182; ឡាវ គឺជាភាគីនៃ C029, C100, C111, C138, C182, C155 and C187; មីយ៉ាន់ម៉ា គឺជាភាគីនៃ C087, C029, C138 and C182; ថៃ គឺជាភាគីនៃ C029, P029, C105, C100, C111, C138,  C182 and C187; វៀតណាម គឺជាភាគីនៃ C098, C029, C105, C100, C111, C138, C182, C155 and C187. សម្រាប់ព័ត៌មានបន្ថែមសូមមើលគេហទំព័រ៖ https://www.ilo.org/dyn/normlex/en/f?p=1000:10011:::NO:10011:P10011_DISPLAY_BY,P10011_CONVENTION_TYPE_CODE:1,F

ច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស ក៏កំណត់ឲ្យរដ្ឋមានកាតព្វកិច្ចមួយដើម្បីធានាថាសហគមន៍និងសាធារណៈជនភាគច្រើនដែលរងផលប៉ះពាល់ អាចទទួលបានព័ត៌មាននិងឱកាស ដើម្បីចូលរួមក្នុងសេចក្តីសម្រេចនានាដែលប៉ះពាល់ពួកគាត់ផងដែរ។

ទាក់ទងនឹងក្រុមហ៊ុនសាជីវកម្ម គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស (ហៅកាត់ថាUNGPs) ដែលជាបទដ្ឋានសកលស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស បានចែងថាក្រុមហ៊ុនសាជីវកម្មមានទំនួលខុសត្រូវក្នុង "ការគោរព" "សិទ្ធិមនុស្សដែលគេទទួលស្គាល់ជាអន្តរជាតិ" ដែលគេយល់ "នៅក្នុងកម្រិតអប្បបរមា" ដូចដែលបានចែងនៅក្នុងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស ដូចជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និង កតិកាសញ្ញា ICESCR និងអនុសញ្ញាស្នូលទាំងប្រាំបីរបស់អង្គការ ILO ដែលមានចែងក្នុងសេចក្តីប្រកាសស្តីពីគោលការណ៍គ្រឹះ និងសិទ្ធិនៅកន្លែងធ្វើការ។

ព័ត៌មានដែលបង្ហាញក្នុងកំណត់សម្គាល់នេះ ទទួលបានពីសមាជិកនៃអង្គការសង្គមស៊ីវិលដែលបានចូលរួមក្នុងកិច្ចប្រជុំតាមប្រព័ន្ធអ៊ីនធឺណែតដែលរៀបចំដោយគណៈកម្មការអ្នកច្បាប់អន្តរជាតិ (ហៅកាត់ថា ICJ) អង្គការ EarthRights International និងអង្គការ Land Watch Thai នៅថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០២២។[6]

ក្រុមសង្គមស៊ីវិលក្នុងតំបន់ បានរាយការណ៍ពីការរំលោភសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ រួមទាំងសិទ្ធិទទួលបានលំនៅដ្ឋាននិងជីវភាពរស់នៅពេញលេញ; ករណីនៃផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន; ការរំលោភសិទ្ធិការងារ; ក៏ដូចជាករណីនៃការខកខានក្នុងការធានាឲ្យមានតម្លាភាព ការពិគ្រោះយោបល់ និងគណនេយ្យភាព ផងដែរ។ របាយការណ៍ទាំងនេះ ត្រូវបានពណ៌នាកាន់តែលម្អិតនៅក្នុងផ្នែកខាងក្រោម។ ក៏មានរបាយការណ៍ដែលចងក្រងនូវឧទាហរណ៍នានាអំពីស្ថាប័នទទួលបន្ទុកផ្នែកអភិវឌ្ឍន៍ដែលគេវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបណ្តាលឲ្យមានការរំលោភសិទ្ធិមនុស្ស និងករណីនានានៃការខកខានរបស់ស្ថាប័នដូចគ្នានេះក្នុងការអនុវត្តវិធានការឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីដោះស្រាយការរំលោភទាំងនេះ។[7]

---

[6] មេធាវីចំនួន 24 រូបដែលជាសមាជិកនៃអង្គការសង្គមស៊ីវិល និងអ្នកសិក្សាមកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម បានចូលរួមក្នុងកិច្ចប្រជុំនេះ។ អ្នកចូលរួម បានស្វែងយល់ពីផលប៉ះពាល់អវិជ្ជមាននាពេលបច្ចុប្បន្ននិងផលប៉ះពាល់ដែលអាចនឹងកើតមាននាពេលអនាគតលើសិទ្ធិមនុស្ស ដែលកើតចេញពីការអនុវត្តក្របខ័ណ្ឌច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសក្នុងប្រទេសរៀងៗខ្លួន។

[7] ជាក់ស្តែង នៅក្នុងករណីនៃតំបន់សេដ្ឋកិច្ចពិសេស Thilawa នៃប្រទេសមីយ៉ាន់ម៉ា, សូមមើល៖ UN Forum on Business & Human Rights, 'Thilawa Special Economic Zone, Myanmar', 2015, មាននៅក្នុងគេហទំព័រ៖ https://www.ohchr.org/sites/default/files/Documents/Issues/Business/ForumSession4/ThilawaSpecialEconomicZoneMyanmar.pdf. សូមមើលផងដែរ៖ Business & Human Rights Resource Centre, 'Myanmar: Thilawa economic zone launches complaint mechanism, NGO says it falls short of intl. standards; inc. responses from company & other agencies', 2018, មាននៅក្នុងគេហទំព័រ៖ https://www.business-humanrights.org/en/latest-news/myanmar-thilawa-economic-zone-launches-complaint-mechanism-ngo-says-it-falls-short-of-intl-standards-inc-responses-from-company-other-agencies/

## ការរំលោភបំពានសិទ្ធិក្នុងការទទួលបានការស្នាក់នៅនិងជីវភាពសមរម្យ

## ការរំលោភបំពានសិទ្ធិក្នុងការទទួលបានលំនៅដ្ឋាននិងជីវភាពសមរម្យ

ការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ជាទូទៅទាមទារឲ្យមានការដកប្រជាជនដែលរស់នៅទីនោះចេញ ដើម្បីអនុញ្ញាតឲ្យអាជីវកម្មថ្មីផ្លាស់ទីចូល។ ការផ្ទេរដីពីសហគមន៍ទៅជាស្ថាប័នអាជីវកម្ម ជារឿយៗត្រូវបានអនុវត្តដោយ  រដ្ឋាភិបាល និង/ឬក្រុមហ៊ុននានា ដោយគ្មានការពិគ្រោះយោបល់សព្វជ្រុងជ្រោយ។ មានរបាយការណ៍អំពីការបណ្តេញចេញទ្រង់ទ្រាយធំ[8] ដែលជួនកាលមានការជូនដំណឹងតិចតួចឬគ្មានការជូនដំណឹងសោះ ដោយបានរំលោភលើបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលហាមឃាត់មិនឲ្យមានការបណ្តេញចេញដោយបង្ខំ។ ដីមួយចំនួនដែលគេ ទទួលបានសម្រាប់សកម្មភាព ឧស្សាហកម្មជាផ្នែកមួយនៃតំបន់សេដ្ឋកិច្ចពិសេសមួយចំនួន ត្រូវបានគេរាយការណ៍ថាមិនលក្ខណៈសមរម្យសម្រាប់សកម្មភាពទាំងនោះឡើយ។ ជាក់ស្តែង តំបន់ដែលបច្ចុប្បន្នគេប្រើប្រាស់សម្រាប់ធ្វើស្រែចំការតាមបែបប្រពៃណី ត្រូវបានបំប្លែងពីតំបន់ជនបទនិងកសិកម្មទៅជាឧស្សាហកម្ម។ [9] លើសពីនេះ សិទ្ធិកាន់កាប់ដីធ្លីតាមទម្លាប់ បែបសមូហភាព ឬបែបប្រពៃណី របស់សហគមន៍ដែលរងផលប៉ះពាល់ ត្រូវបានរំលោភបំពានជាញឹកញាប់ដោយរដ្ឋាភិបាលឬអ្នកអភិវឌ្ឍន៍នៅតំបន់នោះ (ជាទូទៅ សកម្មភាពបែបនេះ មិនត្រូវបានទទួលស្គាល់សមរម្យទាំងស្រុងនៅក្នុងច្បាប់ក្នុងស្រុកនៃរដ្ឋម្ចាស់ផ្ទះឡើយ)។ ដោយមិនគិតពីកម្មសិទ្ធិដីស្របច្បាប់ សំណងដែលផ្តល់ដល់សហគមន៍ និងបុគ្គលដែលរងផលប៉ះពាល់ ជារឿយៗ មិនគ្រប់គ្រាន់ មិនស៊ីសង្វាក់គ្នា ហើយជួនកាលអាស្រ័យលើលទ្ធផលនៃការចរចាដែលមានលក្ខណៈលម្អៀង។

ការគាំទ្រពីដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាលជារឿយៗ មានលក្ខណៈមិនគ្រប់គ្រាន់ទេ។ ជាលទ្ធផល សហគមន៍ជនភៀសខ្លួន ជួបការលំបាកក្នុងជីវភាពរស់នៅ ប្រឈមនឹងកំណើននៃបំណុល ហើយបុគ្គលមួយចំនួនក្លាយជាជនគ្មានផ្ទះសម្បែង ។ ចំណាត់ការព្រហ្មទណ្ឌ ត្រូវបានធ្វើឡើងចំពោះប្រជាពលរដ្ឋដែលតវ៉ាប្រឆាំងនឹងការទិញដីឬដែលមិនព្រមចាកចេញពីដីដែលខ្លួនមាន ជួលឬស្នាក់អាស្រ័យ។

## ផលប៉ះពាល់ធ្ងន់ធ្ងរចំពោះបរិស្ថាន

របាយការណ៍នានា បង្ហាញថាក្រុមហ៊ុនសាជីវកម្មដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍និងការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងបណ្តាប្រទេស CLMTV ជារឿយៗមិនគោរពតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីការការពារបរិស្ថានទេ។ ការអភិវឌ្ឍន៍នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស បានបង្កផលប៉ះពាល់ដល់បញ្ហាបរិស្ថានដែល សហគមន៍ក្បែរនោះ ជួបប្រទះ រួមមាន៖

1. ការបំពុលខ្យល់ចេញពីរោងចក្រ
2. គ្រោះរាំងស្ងួតដែលបណ្តាលមកពីកង្វះទឹក និងភាពតានតឹងរវាងសហគមន៍និងឧស្សាហកម្ម
3. ការចាក់កាកសំណល់ឧស្សាហកម្មចោលខុសច្បាប់ដែលបណ្តាលឲ្យមានការបំពុលទឹកនិងដី

---

[8] ជាក់ស្តែង នៅក្នុងករណីនៃតំបន់សេដ្ឋកិច្ចពិសេស Kyauk Phyu ក្នុងប្រទេសមីយ៉ាន់ម៉ា, សូមមើល៖ ICJ, 'Special Economic Zones in Myanmar: the State Duty to Protect Human Rights', 2017, ទំព័រ 49-68.

[9] ជាក់ស្តែង សូមមើល៖ ICJ, 'The Human Rights Consequences of the Eastern Economic Corridor and Special Economic Zones in Thailand', 2020, នៅទំព័រ 54។

4. ទឹកកាកសំណល់ហូរចេញពីតំបន់ឧស្សាហកម្មចូលក្នុងប្រឡាយក្នុងមូលដ្ឋាននិងតំបន់លំនៅដ្ឋាន និង
5. ការបំផ្លាញប្រព័ន្ធជីវចម្រុះនិងជម្រកសត្វព្រៃដែលបណ្តាលមកពីការសាងសង់និងប្រតិបត្តិការរបស់តំបន់សេដ្ឋកិច្ចពិសេស។

លក្ខខណ្ឌសម្រាប់ការវាយតម្លៃចំពោះផលប៉ះពាល់លើបរិស្ថាន ជារឿយៗត្រូវបានគេចវេសនិងជៀសវាងដោយចេតនា ខណៈដែលក្នុងករណីជាច្រើននៅពេលដែល គេអនុវត្តតាមលក្ខខណ្ឌទាំងនោះ គេ អនុវត្តដោយមិនមានផែនការច្បាស់លាស់ ដោយគ្មានការបង្ហាញជាសាធារណៈ និងដោយមិនមានការចូលរួមច្រើនពីសហគមន៍ដែលរងផលប៉ះពាល់។ ក៏មានរបាយការណ៍នានាដែលបង្ហាញពីការក្លែងបន្លំ ឬការធ្វេសប្រហែសរបស់ក្រុមហ៊ុនក្នុងការអនុវត្តន៍ការវាយតម្លៃលើបរិស្ថាន ផងដែរ។ លើសពីនេះរបាយការណ៍នានា បានចង្អុលបង្ហាញអំពី កង្វះការត្រួតពិនិត្យដោយឯករាជ្យ ក្នុងការដោះស្រាយបញ្ហានៃភាពស្របច្បាប់របស់ភាគីពាក់ព័ន្ធ និង/ឬបញ្ហានៃកង្វះការទទួលខុសត្រូវរបស់អាជ្ញាធរពាក់ព័ន្ធ។

## ការរំលោភបំពានសិទ្ធិការងារ

និយោជក ជារឿយៗមិនអើពើនឹងការការពារច្បាប់ការងារ ហើយ ការអនុវត្ត មានលក្ខណៈទន់ខ្សោយមិនថាក្នុងស្ថានភាពបែបណាឡើយ ខណៈដែលផ្នែកមួយនៃភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេសសម្រាប់អាជីវកម្ម គឺការរៀបចំការងារដែលមានភាពបត់បែនជាងមុន។ កង្វល់សំខាន់ៗដែលគេ បានរាយការណ៍ រួមមាន៖ ប្រាក់ឈ្នួលអប្បបរមាមិនគ្រប់គ្រាន់ក្នុងការធានាឲ្យបាននូវការរស់នៅដ៏សមរម្យ ប្រាក់ឈ្នួលទាប ការបង្ខំឲ្យធ្វើការថែមម៉ោង ការរឹតបន្តឹងថ្ងៃឈប់សម្រាក ការមិនផ្តល់សិទ្ធិឈប់សម្រាកមាតុភាព ការបញ្ឈប់ការងារកម្មករមានផ្ទៃពោះ លក្ខខណ្ឌការងារធ្ងន់ធ្ងរ និងបញ្ហាសុវត្ថិភាព។ ការអនុវត្តការងារដែលមានលក្ខណៈដូចគ្នានឹងទាសភាពដែលរួមទាំងពលកម្មដោយបង្ខំ និងការជួញដូរមនុស្ស ក៏ត្រូវបានរាយការណ៍ផងដែរនៅក្នុងករណីមួយចំនួន។ និយោជកជាច្រើន ត្រូវបានគេរាយការណ៍ថាបានចុះកិច្ចសន្យាការងាររយៈពេលខ្លីជាមួយនិយោជិករបស់ពួកគេ ដែលវាជាមធ្យោបាយសម្រាប់គេចវេសច្បាប់គាំពារសង្គមផ្សេងៗ។ ក្រុមហ៊ុនមួយចំនួន មិនបានចុះបញ្ជីទេ ដែលវាបណ្តាលឲ្យមានការការពារផ្នែកច្បាប់ចំពោះបុគ្គលិករបស់ខ្លួន នៅមានកម្រិត។ យន្តការដោះស្រាយវិវាទបម្រុង ត្រូវបានគេរាយការណ៍ថាមិនអាចយកមកអនុវត្តបានទេ។ សមាជិកសហជីព បានរាយការណ៍ថាមិនអាចជួបជុំដោយសេរី និងពួកគេប្រឈមមុខនឹងការរើសអើងទាក់ទងនឹង លក្ខខណ្ឌស៊ីឈ្នួលនិងលក្ខខណ្ឌការងារ ការបំភិតបំភ័យ ការបណ្តេញចេញ អំពើហឹង្សា និងការបៀតបៀនខាងតុលាការ ដែលជាលទ្ធផលនៃសមាជិកភាពនិងការចូលរួមរបស់ខ្លួនក្នុងសហជីព។

## ការខកខានមិនធានាឲ្យមានតម្លាភាព ការប្រឹក្សាយោបល់ និងគណនេយ្យភាព

កង្វះតម្លាភាព និងគណនេយ្យភាពរបស់ភាគីអាជ្ញាធរនៅក្នុងបណ្តាប្រទេស CLMTV ទាក់ទងនឹងសេចក្តីសម្រេច ការធ្វើផែនការ និងការកសាងតំបន់សេដ្ឋកិច្ចពិសេស ក៏ដូចជាក្នុងដំណាក់កាលប្រតិបត្តិការការអភិវឌ្ឍន៍ គឺជាកង្វល់ទូទៅមួយ។ មនុស្សដែលរងផលប៉ះពាល់ពីតំបន់សេដ្ឋកិច្ចពិសេស មិនត្រូវបានផ្តល់ឱកាសពិតប្រាកដដើម្បីធ្វើសេចក្តីសម្រេចឬសួរដេញដោលអំពីសេចក្តីសម្រេច ដែលទាក់ទងនឹងផែនការគម្រោង ឬការរៀបចំជីវភាពនិងការរស់នៅនាពេលអនាគតនោះទេ។ នៅពេលដែលមានកិច្ចប្រជុំរវាងមន្ត្រីតំបន់សេដ្ឋកិច្ចពិសេសនិងប្រជាពលរដ្ឋ គេ កម្រឃើញសក្តីភាពនៃសេចក្តីសម្រេចឬផែនការដែលគេបានផ្លាស់ប្តូរដើម្បីឆ្លើយតបទៅមតិយោបល់ឬសំណើរបស់ប្រជាពលរដ្ឋណាស់។ កង្វះតម្លាភាពអំពីប្រាក់ចំណូលនិងថវិការ ដែលទទួលបានពីតំបន់សេដ្ឋកិច្ចពិសេសនេះ ច្បាស់ណាស់អាចនឹងបង្កឲ្យមានអំពើពុករលួយ។

ស្ថាប័នគ្រប់គ្រងនិងត្រួតពិនិត្យតំបន់សេដ្ឋកិច្ចពិសេស ជាធម្មតាមានតំណាងមកពីស្ថាប័នរដ្ឋាភិបាល និង/ឬវិស័យធុរកិច្ច។ ដោយគ្មានការពិគ្រោះ ពួកគេ ទទួលអំណាចយ៉ាងទូលំទូលាយ ខណៈពេលដែលពួកគេមិនមានកាតព្វកិច្ចដាក់លាក់ក្នុងការពិគ្រោះយោបល់ជាទៀងទាត់ជាមួយសហគមន៍ដែលរងផលប៉ះពាល់ដើម្បីស្វែងយល់អំពីមតិយោបល់របស់ប្រជាពលរដ្ឋឡើយ។ ជាលទ្ធផល វាជាការពិបាកសម្រាប់អ្នកដែលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីតំបន់សេដ្ឋកិច្ចពិសេស ដើម្បីពិភាក្សា សួរដេញដោល ឬស្វែងរកដំណោះស្រាយចំពោះសេចក្តីសម្រេចផ្នែករដ្ឋបាលនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ លើសពីនេះទៀត ក្នុងករណីជាច្រើន គេ បានរាយការណ៍ថា តំបន់សេដ្ឋកិច្ចពិសេសមួយចំនួន ត្រូវបានយាមការពារយ៉ាងខ្លាំងដោយមន្ត្រីរបស់ក្រុមហ៊ុនវិនិយោគ ហើយគេ ផ្តល់អំណាចតិចតួចទុកឲ្យរដ្ឋាភិបាលនិងមន្ត្រីអនុវត្តច្បាប់នៃប្រទេសម្ចាស់ផ្ទះ ក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យតំបន់នោះ។

**សម្រាប់ព័ត៌មានបន្ថែមនិងករណីសិក្សា៖**

ICJ, 'Special Economic Zones in Myanmar and the State Duty to Protect Human Rights', 2017
(តុលាការព្រហ្មទណ្ឌអន្តរជាតិ, "តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសមីយ៉ាន់ម៉ានិងតួនាទីរបស់រដ្ឋក្នុងការការពារសិទ្ធិមនុស្ស" ឆ្នាំ2017)

ICJ, 'The Human Rights Consequences of the Eastern Economic Corridor and Special Economic Zones in Thailand', 2019
(តុលាការព្រហ្មទណ្ឌអន្តរជាតិ, "ផលប៉ះពាល់លើសិទ្ធិមនុស្សនៃតំបន់ច្រករបៀងសេដ្ឋកិច្ចភាគខាងកើតនិងតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសថៃ" ឆ្នាំ2019)

Kuaycharoen, P., Longcharoen, L., Chotiwan, P., Sukin, K., Lao Independent Researchers, 'Special Economic Zones and Land Dispossession in the Mekong Region', Bangkok: Land Watch Thai, 2020.
(Kuaycharoen, P., Longcharoen, L., Chotiwan, P., Sukin, K., Lao អ្នកស្រាវជ្រាវឯករាជ្យ, "តំបន់សេដ្ឋកិច្ចពិសេសនិងការបណ្តេញចេញពីដីធ្លីនៅក្នុងតំបន់មេគង្គ", ទីក្រុងបាងកក: អង្គការ Land Watch Thai, ឆ្នាំ2020)

Cambodian Center for Human Rights (CCHR), 'Fact Sheet on Cambodia's Special Economic Zones and Human Rights', 2018; and other relevant Briefing Papers.
(មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក), "សលាកបត្រស្ដីអំពីតំបន់សេដ្ឋកិច្ចពិសេសនិងសិទ្ធិមនុស្សនៅប្រទេសកម្ពុជា", ឆ្នាំ2018 និងឯកសារនៃសេចក្ដីសង្ខេបពាក់ព័ន្ធផ្សេងៗទៀត។)

Charlie Thame, 'SEZs and Value Extraction from the Mekong: A Case Study on the Control and Exploitation of Land and Labour in Cambodia and Myanmar's Special Economic Zones, Bangkok: Focus on the Global South, 2017.
(Charlie Thame, "ត..ស.ព និងការទាយកគុណតម្លៃពីតំបន់មេគង្គ: ករណីសិក្សាអំពីការគ្រប់គ្រងនិងការគេងប្រវ័ញ្ចដីធ្លីនិងកម្លាំងពលកម្មនៅប្រទេសកម្ពុជា និងតំបន់សេដ្ឋកិច្ចពិសេសរបស់ប្រទេសមីយ៉ាន់ម៉ា, បាងកង: ការផ្ដោតលើសកលលោកភាគខាងត្បូង, ឆ្នាំ2017)

## អនុសាសន៍

## អនុសាសន៍សម្រាប់រដ្ឋាភិបាលនៅបណ្ដាប្រទេស CLMTV

1. ពិនិត្យមើលហេតុផលផ្នែកសេដ្ឋកិច្ចនៃតំបន់សេដ្ឋកិច្ចពិសេសនិងឥទ្ធិពលរបស់វាមកលើសិទ្ធិមនុស្សរបស់បុគ្គលនិងសហគមន៍ដែលរងផលប៉ះពាល់ និងចាត់វិធានការឲ្យបានគ្រប់គ្រាន់ដើម្បីកែតម្រូវ និងផ្អាកគោលនយោបាយនិងគម្រោងដែលមិនបានផ្ដល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច និង/ឬដែលបំពានច្បាប់អន្តរជាតិ និងច្បាប់ក្នុងស្រុក និងបទដ្ឋាននានាដែលរួមមាន ច្បាប់ និងបទដ្ឋានស្ដីអំពីសិទ្ធិមនុស្ស។

2. ប្រើវិធីសាស្ត្រដែលផ្ដោតលើសិទ្ធិមនុស្ស ចំពោះគម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស និងធានាថាសេចក្ដីសម្រេចត្រូវបានធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយបុគ្គលនិងសហគមន៍ អំពីការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសដែលអាចបង្កគ្រោះថ្នាក់ដល់សហគមន៍និងបរិស្ថានរបស់ពួកគាត់។

3. បង្កើតស្ថាប័នមួយដែលមានអាណត្តិជាក់លាក់ដើម្បីពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់និងភាគីពាក់ព័ន្ធផ្សេងៗទៀត និងត្រូវតាមដានគម្រោង។ ស្ថាប័នបែបនេះ គួរតែរួមបញ្ចូលតំណាងមកពីអង្គការសង្គមស៊ីវិល សហជីព និងសហគមន៍ដែលរងផលប៉ះពាល់។

4. ធានាឲ្យមានតម្លាភាព ដោយផ្សព្វផ្សាយព័ត៌មាននិងឯកសារនានាជាសាធារណៈអំពីតំបន់សេដ្ឋកិច្ចពិសេស

5. ធានាថាការបណ្តេញចេញ គឺជាមធ្យោបាយចុងក្រោយតែប៉ុណ្ណោះ ក្រោយពីបានពិនិត្យមើលលទ្ធភាពនៃជម្រើសផ្សេងៗទៀតសម្រាប់ការបណ្តេញចេញអស់ហើយ។ ការការពារផ្នែកនីតិវិធីដែលទាមទារនៅក្រោមច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស គួរតែមាននិងគួរតែត្រូវបានគោរព មុនពេលអនុវត្តការបណ្តេញចេញណាមួយ ជាពិសេសត្រូវមានលក្ខខណ្ឌនៃការពិគ្រោះយោបល់ពិតប្រាកដ ការការពារឲ្យមានដំណើរការត្រឹមត្រូវ ការផ្តល់ដំណោះស្រាយផ្លូវច្បាប់សំណង និងលំនៅដ្ឋានបម្រុងគ្រប់គ្រាន់។

6. ទទួលស្គាល់គុណតម្លៃផ្នែកសង្គម វប្បធម៌ ស្មារតី សេដ្ឋកិច្ច បរិស្ថាន និងនយោបាយនៃដីធ្លីចំពោះសហគមន៍ និងទទួលស្គាល់សិទ្ធិក្នុងការកាន់កាប់ដីធ្លីតាមទំនៀមទម្លាប់ បែបសមូហភាព ឬបែបប្រពៃណី និងទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការយល់ព្រមដោយសេរី មុននិងក្រោយទទួលបានដំណឹងអំពីការប្រើប្រាស់ដីរបស់ពួកគាត់។

7. ធានាថាការវាយតម្លៃចំពោះផលប៉ះពាល់នៃការបណ្តេញចេញ ត្រូវបានអនុវត្តមុនចាប់ផ្តើមគម្រោងណាមួយដែលអាចបណ្តាលឲ្យមានការបណ្តេញចេញឬមានផលប៉ះពាល់អវិជ្ជមានផ្សេងៗទៀត ដោយមានការពិគ្រោះយោបល់ពិតប្រាកដជាមួយសហគមន៍ដែលរងផលប៉ះពាល់ ហើយត្រូវអនុលោមតាមលក្ខខណ្ឌទាំងអស់នៅក្រោម បទដ្ឋាននិងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស ។

8. ធានាថាការវាយតម្លៃចំពោះផលប៉ះពាល់មកលើបរិស្ថាន និងការវាយតម្លៃចំពោះបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវបានអនុវត្តដោយស្របតាមការអនុវត្តល្អនិងបទដ្ឋានអន្តរជាតិស្តីអំពីសិទ្ធិមនុស្ស។

9. ធានាថាប្រាក់ឈ្នួលអប្បបរមាជាតិ ការពារសិទ្ធិកម្មករនិយោជិកក្នុងការទទួលបានលក្ខខណ្ឌការងារសមរម្យនិងមានយុត្តិធម៌ និងមានលក្ខណៈគ្រប់គ្រាន់ដើម្បីធានាបាននូវការរស់នៅដ៏សមរម្យ។

10. ធានាថាកម្មករនិយោជិកនៅតំបន់សេដ្ឋកិច្ចពិសេស ដោយមិនគិតពីសញ្ជាតិនិងស្ថានភាពចំណាកស្រុក ទទួលបានប្រព្រឹត្តិកម្ម មិនទាបជាងកម្មករផ្សេងទៀត ទាក់ទងនឹងប្រាក់បៀវត្សរ៍ លក្ខខណ្ឌការងារ របបសន្តិសុខសង្គម និងសិទ្ធិទទួលបានការងារសមរម្យស្មើភាពគ្នា ហើយត្រូវស៊ើបអង្កេតនិងដោះស្រាយចំពោះរបាយការណ៍នៃការជួញដូរមនុស្សហើយនិងកម្លាំងពលកម្មដោយបង្ខំនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសជាបន្ទាន់។

11. លុបបំបាត់រាល់ឧបសគ្គផ្នែកច្បាប់និងឧបសគ្គជាក់ស្តែងនានាដែលរារាំងកម្មករមិនឲ្យទទួលបានសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំ និងសិទ្ធិក្នុងការចរចាជាសមូហភាព។

12. ធានាថាមានដំណោះស្រាយតាមប្រព័ន្ធតុលាការនិងក្រៅតុលាការដែលមានប្រសិទ្ធភាព រហ័ស និងអាចស្វែងរកបានជូនដល់អ្នកដែលទទួលរងនូវការរំលោភបំពានសិទ្ធិដោយការអភិវឌ្ឍន៍និងប្រតិបត្តិការរបស់តំបន់សេដ្ឋកិច្ចពិសេស។

13. ធានាឲ្យមានការទ្រទ្រង់គ្រប់គ្រាន់ ផ្តល់ការបណ្តុះបណ្តាល និងពង្រឹងជំនាញ និងការយល់ដឹងរបស់មន្ត្រីនានាទាក់ទងនឹងការផ្តល់ការអនុញ្ញាត អាជ្ញាប័ណ្ណ ឬការយល់ព្រមចំពោះប្រតិបត្តិការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទាក់ទងនឹង

ទិន្នន័យដោយផ្ដោតលើភស្តុតាងស្ដីពីផលប៉ះពាល់បរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ ការវាយតម្លៃការខូចខាត និងការស្តារឡើងវិញនូវធនធានធម្មជាតិដែលខូចខាតឲ្យត្រឡប់មករកស្ថានភាពស្អាតស្អំវិញ។ និង

14. ពង្រឹងសមត្ថភាពនិងឯករាជ្យភាពរបស់តុលាការនិងស្ថាប័នជាតិផ្នែកសិទ្ធិមនុស្ស ដើម្បីធានាថាពួកគេ អាចដើរតួយ៉ាងសកម្មក្នុងការការពារសិទ្ធិមនុស្សក្នុងបរិបទនៃការអភិវឌ្ឍន៍និងប្រតិបត្តិការនៃតំបន់សេដ្ឋកិច្ចពិសេស។

## អនុសាសន៍សម្រាប់អង្គការសហប្រជាជាតិនិងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស

1. ធ្វើការស៊ើបអង្កេត ទស្សនកិច្ច ដោះស្រាយ និងផ្ដល់យោបល់យ៉ាងសកម្ម និងច្បាស់លាស់លើបញ្ហាកង្វល់ដែលកើតឡើងក្នុងបរិបទនៃតំបន់សេដ្ឋកិច្ចពិសេស ដូចជារបាយការណ៍នៃការរំលោភដីធ្លី ការអនុវត្តការងារខុសច្បាប់ ផលប៉ះពាល់ធ្ងន់ធ្ងរលើបរិស្ថាន ការរំលោភសិទ្ធិមនុស្ស ក៏ដូចជាការអះអាងបំភ្លៃអំពីហេតុផលផ្នែកសេដ្ឋកិច្ចនៃតំបន់សេដ្ឋកិច្ចពិសេស;

2. តាមលទ្ធភាពនិងភាពសមស្រប សូមចូលរួមជាមួយតំណាងរាស្ត្រ គណបក្សនយោបាយ មន្ត្រីរដ្ឋាភិបាល និងស្ថាប័នតំបន់សេដ្ឋកិច្ចពិសេស ដើម្បីជំរុញឲ្យមានការអនុម័តនិងការអនុវត្តច្បាប់ គោលនយោបាយ និងការអនុវត្តនានាទាក់ទងនឹងតំបន់សេដ្ឋកិច្ចពិសេសឲ្យស្របតាមបទដ្ឋាននិងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស។ និង

3. ផ្ដល់ជំនួយនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងកិច្ចសហប្រតិបត្តិការក្នុងស្រុក រួមទាំងការទ្រទ្រង់ផ្នែកច្បាប់ បច្ចេកទេស និងបច្ចេកវិទ្យា ដល់អាជ្ញាធរ  រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីឲ្យពួកគាត់អាចធ្វើការតស៊ូមតិបានល្អប្រសើរសម្រាប់ការអនុលោមតាមច្បាប់ស្តីពីសិទ្ធិមនុស្សនៅក្នុងបរិបទនៃតំបន់សេដ្ឋកិច្ចពិសេស។

## អនុសាសន៍សម្រាប់សហគមន៍និងទីភ្នាក់ងារអភិវឌ្ឍន៍

1. ធានាថាជំនួយសម្រាប់ការអភិវឌ្ឍន៍ មិនត្រូវបានផ្តល់ដល់គម្រោងរបស់តំបន់សេដ្ឋកិច្ចពិសេសណា ដែលបង្ហាញពីហានិភ័យពិតប្រាកដនៃការរំលោភសិទ្ធិមនុស្ស ហើយផ្អាកជំនួយសម្រាប់គម្រោងទាំងឡាយណាដែលបំពានលើកាតព្វកិច្ចការពារសិទ្ធិមនុស្ស ដោយរួមបញ្ចូលការយកចិត្តទុកដាក់លើបញ្ហាសិទ្ធិមនុស្សជាចាំបាច់ ដើម្បីធានាថាមធ្យោបាយរបស់តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានបង្កើតឡើងនិងដំណើរការដោយមិនរំលោភបំពានសិទ្ធិមនុស្សឡើយ។

2. ធានាថាគោលនយោបាយវិនិយោគទ្រទ្រង់សិទ្ធិមនុស្ស ការពារបរិស្ថាន ការពារសិទ្ធិការងារ និងមានការអនុលោមរបស់ក្រុមហ៊ុនតាមវិធានការការពារសិទ្ធិ ដូចជាការធានាថាកិច្ចសន្យាប្រាក់កម្ចីមានលក្ខខណ្ឌស្របតាមសិទ្ធិមនុស្ស។ និង

3. ទទួលស្គាល់ដោយបើកចំហថាការរំលោភសិទ្ធិមនុស្ស បានកើតឡើងនៅក្នុងគម្រោងមួយចំនួនដែលបាននិងកំពុងទទួលបានហិរញ្ញប្បទាន ហើយដោះស្រាយបញ្ហារំលោភបំពានបែបនេះ ដោយមានការចូលរួមពីសហគមន៍ដែលរងផលប៉ះពាល់។

## អនុសាសន៍សម្រាប់វិស័យឯកជន

1. អនុវត្តសកម្មភាពអាជីវកម្មទាំងអស់ឲ្យស្របតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស
2. អនុលោមតាមច្បាប់ជាតិទាំងអស់ដែលទាក់ទងនឹងការការពារបរិស្ថាន កម្លាំងពលកម្ម និងសិទ្ធិមនុស្ស ដោយមានវិធាននិងនីតិវិធីពាក់ព័ន្ធ។
3. អនុវត្តការការត្រួតពិនិត្យចំពោះបញ្ហាសិទ្ធិមនុស្ស ដើម្បីធានាថាការវិនិយោគមានលក្ខណៈប្រកបដោយទំនួលខុសត្រូវ និងមិនមានភាពស្មុគស្មាញទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស ដោយរួមមានការធានាថាគេទទួលបានដីដែលកំណត់សម្រាប់គម្រោងតំបន់សេដ្ឋកិច្ចពិសេស ដោយស្របច្បាប់ ហើយធានាថាគេ គោរពសិទ្ធិមនុស្សនៅគ្រប់ដំណើរការទាំងអស់នៃការទទួលបានដីធ្លី និងការបំលែងដីធ្លីដើម្បីប្រើប្រាស់ ក៏ដូចជាគោរពសិទ្ធិមនុស្សពាក់ព័ន្ធនឹងការបណ្តេញប្រជាពលរដ្ឋចេញពីដីផងដែរ។
4. ធានាថាការវាយតម្លៃចំពោះផលប៉ះពាល់មកលើបរិស្ថាន ត្រូវបានអនុវត្តប្រកបដោយភាពឯករាជ្យ មិនលំអៀង ស្របច្បាប់និងមានប្រសិទ្ធភាព។
5. ធានាថានិយោជិកទទួលបានប្រាក់ឈ្នួលគ្រប់គ្រាន់ ត្រូវបានការពារពីការរើសអើងនិងការយាយីនៅកន្លែងធ្វើការ និងមានសិទ្ធិទទួលបានកន្លែងធ្វើការប្រកបដោយសុវត្ថិភាពនិងសុខភាពល្អ។
6. ធានាថានិយោជិកទាំងអស់អាចទទួលបានសិទ្ធិបង្កើតសហជីពនិងសិទ្ធិចូលរួមសហជីពដោយសេរីប្រកបដោយប្រសិទ្ធភាព និងមិនត្រូវទទួលរងនូវការបណ្តេញចេញពីការងារដោយសារការរើសអើងប្រឆាំងនឹងសហជីពឡើយ។
7. បង្កើតយន្តការតវ៉ាផ្នែកប្រតិបត្តិការ (OGM) ដែលអាចប្រើប្រាស់បាននិងមានប្រសិទ្ធភាព ដោយមានការសហការជាមួយសហគមន៍ដែលរងផលប៉ះពាល់ ប្រកបដោយភាពឯករាជ្យ មិនលំអៀង និងមានប្រសិទ្ធភាព។ យន្តការនេះ រួមមានការបង្កើតកាតព្វកិច្ចរបស់ក្រុមហ៊ុនក្នុងការដោះស្រាយកង្វល់របស់បុគ្គល សហគមន៍មូលដ្ឋាន និងកម្មករតំបន់សេដ្ឋកិច្ចពិសេស ដែលរងផលប៉ះពាល់ពីប្រតិបត្តិការរបស់តំបន់សេដ្ឋកិច្ចពិសេស។ និង
8. បញ្ចប់ការបៀតបៀនផ្លូវច្បាប់តាមរយៈការបរិហារកេរ្តិ៍ និងការបំពានលើបុគ្គលនិង/ឬសហគមន៍ដែលរងផលប៉ះពាល់ពីគោលនយោបាយនៃតំបន់សេដ្ឋកិច្ចពិសេស និងអ្នកដែលចង់តវ៉ាបំភ្លឺដោយស្របច្បាប់អំពីការរំលោភសិទ្ធិមនុស្ស។

## អនុសាសន៍សម្រាប់សង្គមស៊ីវិល

1. ត្រួតពិនិត្យ និងចងក្រងឯកសារទាក់ទងនឹងការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស និងចូលរួមក្នុងការតស៊ូមតិដើម្បីធានាថា គេ អាចដំណើរការបានដរាបណាគេធ្វើស្របតាមសិទ្ធិមនុស្សរបស់បុគ្គលនិងសហគមន៍ដែលរងផលប៉ះពាល់ ហើយ រៀបចំផែនការ បង្កើត និងដំណើរការតំបន់សេដ្ឋកិច្ចពិសេសដោយស្របតាមច្បាប់និងបទដ្ឋានអន្តរជាតិនិងក្នុងស្រុក រួមទាំងបទដ្ឋាននិងច្បាប់ស្តីអំពីសិទ្ធិមនុស្សផងដែរ។
2. គាំទ្រសហគមន៍ក្នុងមូលដ្ឋាន កម្មករ និងអ្នកមានសិទ្ធិផ្សេងៗទៀតដើម្បីធានាឲ្យមានការគោរពសិទ្ធិមនុស្ស រួមទាំងសិទ្ធិរបស់ពួកគាត់ក្នុងការប្រឆាំងនឹងតំបន់សេដ្ឋកិច្ចពិសេសដែលគេដាក់ស្នើ។ និង

3. ស្វែងរក និងចូលរួមជាមួយយន្តការនិងស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ដើម្បីពង្រឹងការងារតស៊ូមតិទាក់ទងនឹងតំបន់សេដ្ឋកិច្ចពិសេស។

យើង សូមថ្លែងអំណរគុណចំពោះស្ថាប័នខាងក្រោមដែលផ្តល់នូវការត្រួតពិនិត្យ ការសិក្សាស្រាវជ្រាវ និងការវិភាគដែលទ្រទ្រង់កំណត់សម្គាល់នៃការតស៊ូមតិនេះ។

1. អង្គការលើកលែងទោសអន្តរជាតិ
2. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
3. មជ្ឈមណ្ឌលសម្ព័ន្ធការងារនិងសិទ្ធិមនុស្ស (CENTRAL)
4. អង្គការ Dawei Watch
5. មជ្ឈមណ្ឌល East-West
6. អង្គការ ETO Watch
7. មូលនិធិសិទ្ធិមនុស្សនិងការអភិវឌ្ឍន៍ (HRDF)
8. អង្គការ Mekong Butterfly
9. អង្គការ Mekong Watch
10. មជ្ឈមណ្ឌលសាមគ្គីភាព (Solidarity Center)
11. វិទ្យាស្ថានសន្តិភាពរបស់សហរដ្ឋអាមេរិក (USIP)

និងអ្នកស្រាវជ្រាវ មេធាវី និងដៃគូរទាំងអស់ដែលបានផ្តល់ការវិភាគនិងទស្សនៈនានាដែលបានទ្រទ្រង់ឯកសារបោះពុម្ពផ្សាយនេះ។

EarthRights International · icj International Commission of Jurists · Land Watch Thai